**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០៧៥ សហវ.ករ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៧

**សូមគោរពជូន**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ**: សំណើសុំអនុញ្ញាតផ្ទេរឥណទានថវិកាចំនួន ៦ ២៨១ ១២៦ ០០០ រៀល (ប្រាំមួយប៊ីលានពីររយប៉ែតសិបមួយលានមួយរយម្ភៃប្រាំមួយពាន់រៀលគត់)ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ។

**យោង**: លិខិតលេខ ៦៦៦៩ អយក.ហវ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ និងលិខិតលេខ ៦៦៤៣ អយក.ហវ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្ដេចអគ្គមហាសេនាតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំអនុញ្ញាតផ្ទេរឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ចំនួន ៦ ២៨១ ១២៦ ០០០ រៀល ក្នុងនោះពីផ្នែកអប់រំ ចំនួន ៣ ៤៤០ ០០០ ០០០ រៀល ពីជំពូក ៦០ (ការទិញ) ចំនួន ១ ៣៣៩ ០០០ ០០០ រៀល និងជំពូក ៦១ (សេវាកម្ម ) ចំនួន ២ ១០១ ០០០ ០០០ រៀល និងពីផ្នែកឧត្តមសិក្សាចំនួន ២ ៨៤១ ១២៦ ០០០ រៀល ពីជំពូក ៦០ (ការទិញ )ចំនួន ៨៥០ ០៨៣ ០០០ រៀល និងជំពូក ៦១ (សេវាកម្ម) ចំនួន ១ ៩៩១ ០៤៣ ០០០ រៀល មក ផ្នែកអប់រំ ជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ចំនួន ៦ ២៨១ ១២៦ ០០០ រៀល ដើម្បីចំណាយទិញសម្ភារបរិក្ខារបច្ចេកទេស និងសម្ភារពិសោធន៍បំពាក់នៅតាមសាលារៀន, រៀបចំសន្និបាតកាយរិទ្ធកម្ពុជា, បោះពុម្ពសញ្ញាបត្រមធ្យមសិក្សា និងជំនួយសង្គមផ្សេងៗ ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម**សម្ដេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សូមសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

8.12.17

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការផ្ទេរឥណទានថវិកា

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ចំនួន ៦ ២៨១ ១២៦ ០០០រៀល ក្នុងនោះ ពីផ្នែកអប់រំ ចំនួន ៣ ៤៤០ ០០០ ០០០ រៀល ពីជំពូក ៦០ (ការទិញ ) ចំនួន ១ ៣៣៩ ០០០ ០០០រៀល និងជំពូក ៦១ (សេវាកម្ម ) ចំនួន ២ ១០១ ០០០ ០០០ រៀល និងពីផ្នែកឧត្តមសិក្សា ចំនួន ២ ៨៤១ ១២៦ ០០០រៀល ពីជំពូក ៦០ (ការទិញ) ចំនួន ៨៥០ ០៨៣ ០០០រៀល និងជំពូក ៦១(សេវាកម្ម) ចំនួន ១ ៩៩១ ០៤៣ ០០០ រៀល មក ផ្នែកអប់រំ ជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទៃក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និង កីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ ៥ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយកនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ